Khmer

# សុវត្ថិភាព អគ្គីភ័យតាមផ្ទះ




ព័ត៌មានជំនួយសម្រាប់កិច្ចការពារអគ្គីភ័យនៅក្នុងផ្ទះ

FIRE RESCUE VICTORIA

CFA

# សុវត្ថិភាពអគ្គីភ័យចាប់ផ្តើមនៅផ្ទះ

អគ្គីភ័យនៅក្នុងផ្ទះរបស់អ្នក អាចជាការបំផ្លិចបំផ្លាញថែមបណ្តាលឱ្យស្លាប់ទៀតផង។ ពេលដែលភ្លើងចាប់ផ្តើមហើយនោះ វាអាចរាលដាលយ៉ាងឆាប់រហ័សដែលធ្វើឱ្យអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកប្រឈមនឹងគ្រោះថ្នាក់។ ខណៈពេលដែលគ្រោះថ្នាក់នៃអគ្គីភ័យពិតជាមានមែន មានកិច្ចការជាច្រើនដែលអ្នកអាចធ្វើបានដើម្បីការពារខ្លួនអ្នក គ្រួសារ និងផ្ទះរបស់អ្នក។

សេវាកម្មពន្លត់អគ្គីភ័យ និងជួយសង្គ្រោះរបស់វិចថូរៀ ប្តេជ្ញារក្សាសហគមន៍ឱ្យមានសុវត្ថិភាពតាមរយៈការចែករំលែកយុទ្ធសាស្ត្រសុវត្ថិភាពអគ្គីភ័យតាមផ្ទះ និងព័ត៌មាន ជាមួយពលរដ្ឋ វិចថូរៀ។

កុមារតូចៗ មនុស្សចាស់ មនុស្សពិការ និងអ្នកជក់បារី មានហានិភ័យខ្ពស់ក្នុងការរងរបួស ឬមិនរស់រានមានជីវិតពីអគ្គីភ័យនៅក្នុងផ្ទះរបស់ពួកគេ។

ដំបូន្មាននៅក្នុងកូនសៀវភៅនេះ នឹងជួយអ្នកឱ្យរៀនពីវិធីដែលអ្នកអាចការពារអគ្គីភ័យតាមផ្ទះ និងការពារអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកឱ្យមានសុវត្ថិភាព។ ការធ្វើឱ្យមានសុវត្ថិភាពអគ្គីភ័យតាមផ្ទះរបស់ និងការយល់ដឹងពីអ្វីដែលត្រូវធ្វើក្នុងករណីមានអគ្គីភ័យ អាចជាភាពខុសគ្នារវាងជីវិត និងសេចក្តីស្លាប់។

សូមឃ្លាំមើលនិមិត្តសញ្ញានេះដែលគូសបញ្ជាក់ពីសារសុវត្ថិភាព ឬព័ត៌មានជំនួយដ៏សំខាន់ៗ !






- មានឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងដែលដំណើរការ ហើយធ្វើតេស្តវាឱ្យបានទៀងទាត់។
- ប្រយ័ត្នចំពោះគ្រោះថ្នាក់អគ្គីភ័យនៅក្នុងផ្ទះ។
- មានផែនការរត់គេចពីអគ្គីភ័យនៅផ្ទះ ហើយហាត់អនុវត្តវាឱ្យបានទៀងទាត់។
- ប្រសិនបើមានអគ្គីភ័យកើតឡើងនៅក្នុងផ្ទះរបស់អ្នក សូមចេញក្រៅនៅខាងក្រៅ ហើយហៅទូរស័ព្ទលេខសូន្យបីដង (000)។

# ភ្លើងឆេះលឿនណាស់!






៣០វិនាទី

មកទល់នឹងពេលនេះ ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងគួរតែបានរកឃើញអគ្គីភ័យ ហើយបានជូនដំណឹងដល់ក្រុមគ្រួសាររបស់អ្នក។






៦០វិនាទី

ដោយគ្មានការព្រមាន ភ្លើងចាប់ផ្តើមឆេះរាលដាលដែលមិនអាចគ្រប់គ្រងបាន។ វានឹងមានអនុភាពយ៉ាងឆាប់រហ័សដោយបញ្ចេញនូវផ្សែងពុល។






៣នាទី

អគ្គីភ័យបានឡើងដល់កម្រិតលើសពី៨០០អង្សាសេ។ គ្រប់របស់របរទាំងអស់នៅក្នុងបន្ទប់នឹងត្រូវឆេះ ហើយវានឹងរាលដាលដល់បន្ទប់ផ្សេងទៀតនៅក្នុងផ្ទះ។

រូបថតមានការអនុញ្ញាតពី TFS (សេវាកម្មពន្លត់អគ្គីភ័យ ថាស្មានៀ)

# ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង



**!** មានតែឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង ដែលដំណើរការប៉ុណ្ណោះ ដែលជួយសង្គ្រោះជីវិត។

អ្នកទំនងជាស្លាប់នៅក្នុងអគ្គីភ័យក្នុងលំនៅដ្ឋានដែលគ្មានឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង ដែលមិនដំណើរការ។

ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងដែលដំណើរការ ផ្តល់ឱ្យអ្នកនូវការព្រមានជាមុនអំពីអគ្គីភ័យ និងផ្តល់ឱ្យអ្នកនូវពេលវេលាដើម្បីរត់គេចដោយសុវត្ថិភាព។ អ្នកគួរតែមានឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យ ឬផ្សែង យ៉ាងហោចណាស់មួយនៅតាមជាន់ផ្ទះនីមួយៗរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែមអំពី ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង សូមចូលមើលនៅតាមវិបសៃថ៍ frv.vic.gov.au និង cfa.vic.gov.au

សេវាកម្មត្រួតពិនិត្យឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងផ្ទាល់ខ្លួនមួយចំនួនដែលប្រើដោយមនុស្សចាស់ ឬជនពិការ អាចរួមបញ្ចូលតំណភ្ជាប់ទៅនឹងឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង។ នេះនឹងចាំបាច់ត្រូវពិនិត្យជាមួយអ្នកផ្តល់សេវាកម្មរបស់អ្នក។ ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងដែលផលិតជាពិសេស អាចរកបានសម្រាប់មនុស្សថ្លង់ ឬពិបាកស្តាប់។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសៃថ៍ expression.com.au




- ប្រសិនបើអ្នកមានឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង ដែលមានថ្មពិល៩វ៉ុល ចូរផ្លាស់ជំនួសថ្មពិលជារៀងរាល់ឆ្នាំ។
- បោសសម្អាតធូលីនៅជុំវិញគម្របខាងក្រៅ ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងរបស់អ្នក យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។
- ប្រសិនបើ ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងរបស់អ្នកបញ្ចេញសម្លេងប៊ីបតែម្តង ហើយម្តងម្កាល អ្នកចាំបាច់ត្រូវផ្លាស់ប្តូរថ្មពិល ឬក៏ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង ប្រហែលជាខូច ហើយត្រូវផ្លាស់ជំនួស។



# សេវាកម្មពន្លត់អគ្គីភ័យអូស្ត្រាលីណែនាំឱ្យដំឡើង ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង នៅគ្រប់តំបន់រស់នៅតាមផ្លូវដើរក្នុងផ្ទះ និងបន្ទប់គេង។

ដំឡើងឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង ជាមួយថ្មពិល ដែលមានអាយុកាល១០ឆ្នាំ។

សេវាកម្មពន្លត់អគ្គីភ័យ និងជួយសង្គ្រោះវិចថូរៀណែនាំថា ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង ត្រូវតែបានតភ្ជាប់ ដូច្នេះនៅពេលមានឧបករណ៍បន្លឺសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងណាមួយរោទិ៍ នោះឧបករណ៍បញ្ចេញសម្លេងនៅពេលមាន អគ្គីភ័យឬផ្សែង ទាំងអស់នឹងបន្លឺសម្លេងព្រមគ្នាដែរ។

ពេលណាអ្នកដេកលក់ អ្នកនឹងបាត់បង់អារម្មណ៍ដឹងក្លិន។ ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងដែលដំណើរការ នឹងប្រាប់អ្នកឱ្យដឹងមុន ប្រសិនបើមានផ្សែងចេញពីភ្លើង។




ដើម្បីធ្វើតេស្ត សូមចុចប៊ូតុងធ្វើតេស្តនៅលើឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង រៀងរាល់ខែហើយរង់ចាំវាបន្លឺសម្លេង 'ប៊ីប ប៊ីប ប៊ីប'។ ប្រសិនបើវាបន្លឺសម្លេង នេះមានន័យថាឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង របស់អ្នកនៅដំណើរការទេ។



ដាក់ជំនួសរាល់ឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែង រៀងរាល់ ឆ្នាំជាមួយថ្មពិល lithium។




ដំឡើងនៅលើពិដាននៅតាមជាន់ផ្ទះនីមួយៗ យ៉ាងហោចណាស់៣០សម ពីជញ្ជាំង។

# ផែនការពន្លត់អគ្គីភ័យនៅផ្ទះ

មិនថាអ្នករស់នៅក្នុងផ្ទះបែបណានោះឡើយ វាចាំបាច់ណាស់ដែលអ្នកត្រូវដឹងថាតើត្រូវធ្វើអ្វីប្រសិនបើមានអគ្គីភ័យកើតឡើង។






*ប្រសិនបើអ្នកឃើញមានអគ្គីភ័យ ត្រូវគេចចេញ ហើយកុំចូលក្នុងឱ្យសោះ*

- រក្សាច្រកចេញរបស់អ្នកឱ្យបានស្រឡះល្អ។
- ត្រូវទុកកូនសោជាប់នឹងទ្វារចាក់សោជាប់ និងទ្វារសុវត្ថិភាពជានិច្ច ពេលណាអ្នកនៅខាងក្នុង ដើម្បីឱ្យអ្នកអាចរត់គេចបានប្រសិនបើមានអគ្គីភ័យកើតឡើង។

## ❗ វាមានសារៈសំខាន់ណាស់ដែលត្រូវមានផែនការរត់គេចពីអគ្គីភ័យនៅផ្ទះក្នុងករណីមានអាសន្ន។

- បន្ទាបខ្លួនឱ្យទាប ហើយនៅឱ្យបានឆ្ងាយពីផ្សែង។
- ប្រាប់មនុស្សដទៃទៀតឱ្យបានដឹងពេលរត់គេចទៅក្រៅ។
- ប្រសិនបើមានសុវត្ថិភាពដើម្បីធ្វើដូច្នេះ បិទទ្វារនៅពេលអ្នកចាកចេញ។
- ត្រូវគេចចេញ ហើយកុំចូលក្នុងឱ្យសោះ។
- ជួបជុំគ្នានៅកន្លែងមានសុវត្ថិភាព នៅខាងក្រៅផ្ទះរបស់អ្នក ឧទាហរណ៍ ប្រអប់សំបុត្រ ឬផ្លូវដើរ។
- ហៅទូរស័ព្ទលេខសូន្យបីដង (000) ហើយស្នើសុំ FIRE (ហ្វាយអ៊ើ - អគ្គីភ័យ)។




ផែនការរត់គេចពីអគ្គីភ័យនៅផ្ទះដែលបានគ្រោងទុក និងហាត់អនុវត្តតាម អាចជួយសង្គ្រោះជីវិតអ្នក សូមមើលទំព័រ 19។




ត្រូវប្រាកដថាលេខផ្ទះរបស់អ្នក អាចមើលឃើញយ៉ាងច្បាស់ពីផ្លូវថ្នល់។



ប្រសិនបើអ្នករស់នៅក្នុងអាគារខ្ពស់ៗ ត្រូវដឹងពីកន្លែងច្រករត់គេចក្នុងពេលមានអគ្គីភ័យ ហើយត្រូវប្រើជណ្តើរជានិច្ច។

## ប្រសិនបើអ្នកមិនអាចរត់គេច ...

- ប្រសិនបើវាមានសុវត្ថិភាព បិទទ្វារបន្ទប់ដែលភ្លើងកំពុងឆេះ។
- នៅឱ្យបានឆ្ងាយពីផ្សែង និងអគ្គីភ័យ តាមដែលអាចធ្វើទៅបាន។
- ហៅទូរស័ព្ទលេខសូន្យបីដង (000) ហើយស្នើសុំ FIRE (ហ្វាយអ៊ើ - អគ្គីភ័យ) ហើយនិយាយថាអ្នកត្រូវការជំនួយដើម្បីចេញទៅខាងក្រៅ - កុំទម្លាក់ទូរស័ព្ទឱ្យសោះ។



# អគ្គិសនី



អគ្គីភ័យបង្ករដោយអគ្គីភ័យ គឺជាប្រភេទនៃអគ្គីភ័យទូទៅនៅក្នុងផ្ទះ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីសុវត្ថិភាពអគ្គីសនី សូមចូលមើលវ៉ិបសែថ៍ សុវត្ថិភាពថាមពល វិចថូរៀ ( Energy Safe Victoria ) esv.vic.gov.au

*ប្រសិនបើវាជាអគ្គិសនី ត្រូវរក្សាឱ្យមានសុវត្ថិភាព និងត្រួតពិនិត្យវា*

- រាល់ឧបករណ៍អគ្គិសនីទាំងអស់គួរតែមានស្លង់ដារអូស្ត្រាលី ឬសញ្ញាសម្គាល់ការអនុវត្តតាមបទបញ្ញា ( RCM )។
- ត្រូវប្រាកដថាបន្ទះដោតចរន្តអគ្គិសនី មានឧបករណ៍ការពារការផ្ទុកហួសកម្លាំងអគ្គិសនី ហើយមិនត្រូវដាក់អ្វីគ្របពីលើវាទេ ឧទាហរណ៍ ខ្នើយ និងខ្នើយឱប។



# វត្ថុប្រើប្រាស់អគ្គិសនីនៅក្នុងផ្ទះ អាចរួមបញ្ចូលទាំងការផ្គត់ផ្គង់ថាមពលឧបករណ៍ប្រើប្រាស់អគ្គិសនីថេរ ឧបករណ៍ប្រើប្រាស់អគ្គិសនីដែលអាចផ្លាស់ទីកន្លែង បន្ទះដោតចរន្តអគ្គិសនី និងខ្សែភ្លើងបន្ត។

វាមានសារៈសំខាន់ណាស់ក្នុងការរក្សាឱ្យមានចរន្តខ្យល់ចេញចូលល្អ ជុំវិញវត្ថុ និងឧបករណ៍ប្រើប្រាស់អគ្គិសនី ហើយយកចេញនូវវត្ថុអ្វីៗដែលនៅជុំវិញ ឬខាងលើឧបករណ៍ប្រើប្រាស់អគ្គិសនីទាំងនោះ។

ប្រើដាងអគ្គិសនីដែលមានសញ្ញាបត្រត្រឹមត្រូវប៉ុណ្ណោះ ដើម្បីជួសជុលឧបករណ៍អគ្គិសនីដែលខូច ឬមិនដំណើរការ។




ដោតឧបករណ៍អេឡិចត្រូនិចមួយ ក្នុងបន្ទះចែកចាយចរន្តភ្លើងមួយប៉ុណ្ណោះ។ កុំដោត 'ត្រួតពីលើគ្នា' ទៅក្នុងរន្ធតែមួយ ឬប្រើក្បាលចែកចាយចរន្តភ្លើងមានកន្លែងស៊កពីរ។



ត្រូវប្រាកដថាឧបករណ៍ប្រើប្រាស់អគ្គិសនី ដូចជាម៉ាស៊ីនសម្ងួតសក់ ម៉ាស៊ីនធ្វើសក់ឱ្យត្រង់ និងកុំព្យូទ័រយួរដៃ មិនបានទុកចោលនៅលើផ្ទៃដែលអាចឆេះ។



ប្រើប្រាស់តែឧបករណ៍បញ្ចូលភ្លើងដែលបានយល់ព្រមប៉ុណ្ណោះ។ បញ្ចូលភ្លើងវត្ថុនៅលើផ្ទៃដែលមិនឆេះ ហើយដកវាចេញភ្លាមៗពេលណាបានបញ្ចូលភ្លើងពេញហើយ។



តែងតែឱ្យម៉ាស៊ីនសម្ងួតសម្លៀកបំពាក់បញ្ចប់វដ្តត្រជាក់ មុនពេលបញ្ឈប់វា។ លាងសមាតតម្រងកំទេចធូលីបោក មុនពេលប្រើវាម្តងៗ។

# ផ្ទះបាយ និងការចម្អិនអាហារ

ផ្ទះបាយគឺជាបន្ទប់ដែលមានអគ្គីភ័យភាគច្រើនកើតឡើងនៅក្នុងផ្ទះ។



! ការចម្អិនអាហារដែលត្រូវបានទុកចោលគ្មានមនុស្ស នៅឃ្លាំមើល គឺជាមូលហេតុទូទៅបំផុតនៃអគ្គីភ័យនៅក្នុងផ្ទះបាយ ដូច្នេះត្រូវប្រាកដថានៅមើលវា ពេលណាអ្នកកំពុងចម្អិនអាហារ។



## *រក្សាការឃ្លាំមើល នៅពេលកំពុងចម្អិនអាហារ។*

- ពិនិត្យមើលថាចង្ក្រាន stove, ចង្ក្រាន cooktop, ចង្ក្រានដុតសាច់ និងប្រភពកំដៅផ្សេងទៀត ត្រូវបានបិទមុនពេលចាកចេញពីផ្ទះ ឬចូលគេង។
- កុំប្រើទឹកដើម្បីពន្លត់ប្រេង ឬខ្លាញ់។
- ត្រូវត្រួតពិនិត្យកុមារនៅក្នុងផ្ទះបាយជានិច្ច។




ទុកដាក់វត្ថុដែលអាចឆេះបាន យ៉ាងហោចណាស់១ម៉ែត្រពីកន្លែងចម្អិនអាហារ និងប្រភពកំដៅ។




ឧបករណ៍ពន្លត់អគ្គីភ័យ និងភួយពន្លត់អគ្គីភ័យ គួរតែមាននៅគ្រប់ផ្ទះបាយ។ ប្រើប្រាស់វា ប្រសិនបើអ្នកគិតថាវាមានសុវត្ថិភាពប៉ុណ្ណោះ។



រក្សាចង្ក្រាន stovetop, ចង្ក្រានអាំងសាច់ តម្រងស្រូបផ្សែង និងកន្លែងចម្អិនអាហារកុំឱ្យមានកំណកខ្លាញ់ និងប្រេង។

# ការដុតកំដៅ

## កំដៅគឺជាបុព្វហេតុចំបងនៃអគ្គីភ័យ ជាពិសេសក្នុងអំឡុងខែរដូវរងារ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលវិបសៃថ៍ សុវត្ថិភាពថាមពល វិចថូរៀ
( Energy Safe Victoria ) esv.vic.gov.au






- ត្រូវប្រាកដថាម៉ាស៊ីនកំដៅផ្ទះ រួមទាំងបំពង់បង្ហុយផ្សែង និងបំពង់បង្ហុយផ្សែងពីភ្លើងដុតកំដៅក្នុងផ្ទះ ត្រូវបានជូតសម្អាត និងត្រួតពិនិត្យជាប្រចាំដោយអ្នកបច្ចេកទេសដែលមានច្បាប់អនុញ្ញាត។
- បិទម៉ាស៊ីនកំដៅ និងពន្លត់ភ្លើងដែលគ្មានអ្វីបិទបាំង មុនពេលចាកចេញពីផ្ទះ ឬចូលគេង។






ទុកវត្ថុដែលអាចឆេះបានយ៉ាងហោចណាស់១ម៉ែត្រ ពីប្រភពកំដៅទាំងអស់។



ពិនិត្យមើលថារងើកភ្លើងត្រជាក់ មុនពេលបោះចោលវា។



ត្រួតពិនិត្យកុមារពេលណាពួកគេនៅក្បែរឧបករណ៍កំដៅ និងភ្លើងដែលគ្មានអ្វីបិទបាំង។

# បារី និងអណ្តាតភ្លើងដែលគ្មានអ្វីបិទបាំង

បារី ទៀន ធូប និងឧបករណ៍ដុតប្រេងអាចបង្កឱ្យមានអគ្គីភ័យ។ ត្រូវពន្លត់អណ្តាតភ្លើង ឬភ្លើងបារីដែលគ្មានអ្វីបិទបាំងជានិច្ច មុនពេលចាកចេញពីផ្ទះ ឬចូលគេង។

❗ ប្រើតែទៀន ធូប និងឧបករណ៍ដុតប្រេងនៅលើផ្ទៃដែលមានស្ថេរភាពដែលនឹងមិនឆេះប៉ុណ្ណោះ។






## *ពន្លត់វា កុំផ្ទាត់វា*

- កុំដក់បារីនៅលើគ្រែ។ ការដក់បារីនៅលើគ្រែ គឺជាមូលហេតុមួយដែលបណ្តាលឱ្យស្លាប់ដោយសារភ្លើងឆេះ។
- អណ្តាតភ្លើងដែលគ្មានអ្វីបិទបាំង គួរតែត្រូវបានត្រួតពិនិត្យជានិច្ច។
- ទុកដែកកេះ ឈើគូស ទៀន ធូប និងឧបករណ៍ដុតប្រេងឱ្យផុតពីដៃកុមារ។
- ពិចារណាពីជម្រើសជំនួសអណ្តាតភ្លើងទៀនដែលគ្មានអ្វីបិទបាំង ឧទាហរណ៍ ទៀនដំណើរការដោយថ្មពិល។



ពន្លត់ភ្លើងបារីនៅក្នុងចានគោះកំទេចបារីដែលធ្ងន់ ហើយមានរាងខ្ពស់ និងដើម្បីធានាថាវារលត់ មុនពេលបោះចោលវា។




រក្សាវាំងនន និងវត្ថុផ្សេងទៀតដែលអាចឆាបឆេះ យ៉ាងហោចណាស់១ម៉ែត្រពីអណ្តាតភ្លើងដែលគ្មានអ្វីបិទបាំង ។



ប្ញារីដែលបោះចោលដោយមិនប្រុងប្រយ័ត្ន បានបណ្តាលឱ្យកើតមានអគ្គិភ័យធំៗ នៅក្នុងអាគារច្រើនជាន់ៗ

ពន្លត់វា កុំផ្ទាត់វា ជាពិសេសប្រសិនបើអ្នករស់នៅក្នុងអាគារច្រើនជាន់។

# នៅខាងក្រៅផ្ទះ

ផ្ទះរបស់អ្នកអាចមានយ៉រ ធ្លា រោង អាគារចតរថយន្ត ឬជាន់ដាក់ទំនិញនៅក្នុងក្រៅផ្ទះ។ អគ្គីភ័យអាចកើនឡើងយ៉ាងឆាប់រហ័សដោយសារតែវត្តមាននៃវត្ថុទាំងឡាយដូចជាស៊ីឡាំងឧស្ម័ន កំប៉ុងប្រេងឥន្ធនៈ និងសារធាតុគីមីផ្សេងទៀត។






ធានាថាទុយោហ្គាសដែលតភ្ជាប់នឹងចង្ក្រានបាប៊ីឃ្យូមិនទាន់ខូតខាតទេ ហើយការតភ្ជាប់ត្រូវបានរឹតបន្តឹងល្អ។ ពិនិត្យមើលការលេចធ្លាយ ជាមួយទឹកសាប៊ូ។



លាងសម្អាតកំណកប្រេង និងខ្លាញ់ដែលនៅជាប់ចង្ក្រានបាប៊ីឃ្យូឱ្យបានទៀងទាត់ រួមទាំងថាសទ្រដំណក់ខ្លាញ់។




ប្រើតែចង្ក្រានបាប៊ីឃ្យូសម្រាប់ប្រើនៅទីខាងក្រៅប៉ុណ្ណោះ និងរក្សាចម្ងាយយ៉ាងហោចណាស់៥០សមពីជញ្ជាំង ឬរបងទាំងអស់។ កុំទុកចោលការចម្អិនអាហារដោយគ្មានមនុស្សនៅឃ្លាំមើល។

## រក្សាទុកសារធាតុគីមីរបស់អ្នកដោយសុវត្ថិភាព

- នៅក្នុងរោង ឬអាគារចតរថយន្តរបស់អ្នក សូមរក្សាទុកផលិតផលគីមីដូចជាប្រេងឥន្ធនៈដោយសុវត្ថិភាព នៅឆ្ងាយពីប្រភពនៃការបញ្ឆេះ ហើយឱ្យផុតពីដៃកុមារ។
- ប្រសិនបើអ្នកលែងត្រូវការវាទៀតហើយ ចូរបោះចោលសារធាតុគីមីឱ្យបានត្រឹមត្រូវ និងសុវត្ថិភាព។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល sustainability.vic.gov.au/You-and-your-home/Waste-and-recycling/Detox-your-home

# បញ្ជីត្រួតពិនិត្យសុវត្ថិភាពអគ្គីភ័យ ☑

- ត្រូវមានឧបករណ៍បញ្ចេញសម្លេងនៅពេលមានអគ្គីភ័យឬផ្សែងដែលដំណើរការ ហើយធ្វើតេស្តវាឱ្យបានទៀងទាត់។
- ត្រូវមានផែនការរត់គេចពីអគ្គីភ័យនៅផ្ទះដែលបានគ្រោងទុក និងហាត់អនុវត្តតាម
- រក្សាការឃ្លាំមើល នៅពេលកំពុងចម្អិនអាហារ។.
- ដោតឧបករណ៍អេឡិចត្រូនិចមួយ ក្នុងបន្ទះចែកចាយចរន្តភ្លើងមួយប៉ុណ្ណោះ ( មិនមានក្បាលចែកចាយចរន្តភ្លើងមានកន្លែងស៊កពីរទេ )។
- រក្សាច្រកចេញឱ្យបានស្រឡះល្អ។
- ទុកដាក់វត្ថុទាំងអស់ដែលអាចឆេះបានយ៉ាងហោចណាស់១ម៉ែត្រពីប្រភពកំដៅ។
- ទុកដាក់ដែកកេះ ឈើគូស ទៀន ធូប ឧបករណ៍ដុតប្រេង និងបារីឱ្យផុតពីដៃកុមារ។
- ទុកដាក់សារធាតុគីមីឱ្យឆ្ងាយពីប្រភពបញ្ឆេះ និងផុតពីដៃកុមារ។
- ត្រូវទុកកូនសោជាប់នឹងទ្វារចាក់សោជាប់ និងទ្វារសុវត្ថិភាពជានិច្ច ពេលណាអ្នកនៅខាងក្នុង ដើម្បីឱ្យអ្នកអាចរត់គេចបានប្រសិនបើមានអគ្គីភ័យកើតឡើង។






## ហ្អៃពួកក្មេងៗ ចូរគូរប្លង់ផែនការរត់គេចពីអគ្គីភ័យនៅផ្ទះរបស់ពួកឯង ជាមួយមនុស្សធំ

! វាមានសារៈសំខាន់ណាស់ដែលត្រូវមានផែនការរត់គេចពីអគ្គីភ័យនៅផ្ទះ ដើម្បីឱ្យអ្នកដឹងពីរបៀបចាកចេញពីផ្ទះយ៉ាងឆាប់រហ័សក្នុងករណីមានអាសន្ន។

អាសយដ្ឋានរបស់អ្នក

..............................................................

..............................................................

..............................................................

ចំណុចជួបជុំគ្នាដោយសុវត្ថិភាព

..............................................................

..............................................................

..............................................................

**រៀបផែនការរត់គេចរបស់អ្នកៗ ចងចាំពីចំណុចសំខាន់ៗទាំងនេះ៖**

- ដឹងផ្លូវពីរចេញ ពីបន្ទប់នីមួយៗ។
- បិទទ្វារដើម្បីការពារភ្លើង និងផ្សែងពីការរាលដាល។
- លូនទាបនៅក្នុងផ្សែង។
- រត់គេចចេញ។ ប្រាប់អ្នកដទៃទៀតឱ្យបានដឹង។
- ពេលនៅខាងក្រៅ ចូររក្សានៅខាងក្រៅ។ កុំត្រឡប់ទៅក្នុងវិញឱ្យសោះ!
- ជួបជុំគ្នានៅកន្លែងជួបជុំធម្មតានៅខាងមុខផ្ទះ៖ ឧទាហរណ៍ ប្រអប់សំបុត្រ។ រង់ចាំរហូតដល់កងពន្លត់អគ្គីភ័យមកដល់។
- ហៅទូរស័ព្ទលេខសូន្យបីដង (000) ពីទូរស័ព្ទដែលមាននៅជិតបំផុតៈ ឧទាហរណ៍ ផ្ទះអ្នកជិតខាង។

**ឧទាហរណ៍នៃផែនការរត់គេចពីអគ្គីភ័យនៅផ្ទះៗ**



# ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវិបសៃថ៍ដូចខាងក្រោមនេះ៖

## សេវាកម្មពន្លត់អគ្គីភ័យ

សេវាកម្មសង្គ្រោះអគ្គីភ័យ វិចថូរៀ ( FRV )
frv.vic.gov.au

អាជ្ញាធរពន្លត់អគ្គីភ័យក្រៅក្រុង ( CFA )
cfa.vic.gov.au

## វិបសៃថ៍ផ្សេងទៀត

សុវត្ថិភាពថាមពល វិចថូរៀ ( ESV )
esv.vic.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងនិយាយ ( TIS )
www.tisnational.gov.au/en/Non-English-speakers/Help-using-TIS-National-services/Immediate-telephone-interpreting-for-non-English-speakers

VicEmergency
emergency.vic.gov.au

Expression Australia
expression.com.au

ក្រសួងសុខាភិបាល និងសេវាកម្មមនុស្ស ( DHHS )
dhhs.vic.gov.au

Kidsafe Victoria
kidsafevic.com.au

ការគ្រប់គ្រងគ្រោះអាសន្ន វិចថូរៀ ( EMV )
emv.vic.gov.au

និរន្តរភាព វិចថូរៀ
sustainability.vic.gov.au

អាជ្ញាធរសំណង់ វិចថូរៀ
vba.vic.gov.au

